# CASTOR INTERNATIONAL

ផែនការនៃការកាន់កាប់ភាគហ៊ុនរបស់និយោជិតជាអន្តរជាតិ

(International Group Share Ownership Plan) របស់ VINCI group

# ពាក្យស្នើសុំចុះឈ្មោះទិញភាគហ៊ុន

**សម្រាប់ការផ្តល់ជូនដល់និយោជិតក្នុងឆ្នាំ ២០២២**

**សូមប្រគល់លិខិតនេះទៅអោយ** VINCI

**យ៉ាងយូរបំផុតត្រឹមថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២២**

**ខ្ញុំ** ☐ លោក ☐ លោកស្រី

គោត្តនាមៈ ................................................ នាមៈ ..........................................

ថ្ងៃខែឆ្នាំកំណើតៈ |_|_|_|_|_|_|_|_| សញ្ជាតិៈ ....................អត្តលេខក្នុង VINCI group' |_|_|_|_|_|_|_|

លេខលិខិតឆ្លងដែន/អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់និយោជិតៈ |_|_|_|_|_|_|_|_|_|_|_| និយោជកៈ

..............................................................................................................

..............................................................................................................

អាសយដ្ឋានផ្ទាល់ខ្លួនៈ ...........................................................................................

..............................................................................................................

លេខកូដប្រៃសណីយ៍ (Postal Code)៖........... ទីក្រុងៈ .................. ប្រទេសៈ ..

អ៊ីមែលៈ............................ ..................................................... លេខទូរសព្ទដៃៈ..............................

ព័ត៌មានដែលតម្រូវឱ្យមានខាងលើនេះ មានសារៈសំខាន់ក្នុងដំណើរការពាក្យស្នើសុំចុះឈ្មោះទិញភាគហ៊ុនរបស់លោកអ្នក និងក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់លោកអ្នក។ សូមបំពេញគ្រប់ចន្លោះទាំងអស់មុននឹងបញ្ជូនពាក្យស្នើសុំចុះឈ្មោះទិញនេះរបស់លោកអ្នក។

- សូមបញ្ជាក់ដូចបានរៀបរាប់ខាងក្រោមៈ
  - ខ្ញុំបានអាន និងបានយល់នូវឯកសារពាក់ព័ន្ធនឹងការផ្តល់ជូន ដែលខ្ញុំអាចទទួលបាន និងជា ពិសេសខិត្តប័ណ្ណព័ត៌មានសង្ខេប (Information Brochure) និងឯកសារបន្ថែមតាមប្រទេស (Country Supplement) ព្រមទាំងឯកសារ ព័ត៌មានស្តីពីវិនិយោគិនសំខាន់របស់ FCPE CASTOR INTERNATIONAL RELAIS 2022 និង FCPE CASTOR INTERNATIONAL ដែលអាចរកបានក្នុង https://castor.vinci.com (រួមទាំងឯកសារស្នើសុំជាភាសាខ្មែរ)។
  - ខ្ញុំបានទទួលដំណឹងអំពីតម្លៃនៃការទិញភាគហ៊ុននេះ។
  - ខ្ញុំឯកភាពយល់ព្រមថា ខ្ញុំជាប់កាតព្វកិច្ចគោរពតាមសេចក្តីអះអាង និងការសន្យាដែលមានចែងនៅខាងខ្នងនៃពាក្យស្នើសុំនេះ។
- ខ្ញុំសូមបញ្ជាក់បន្ថែមទៀតថា នៅថ្ងៃធ្វើពាក្យស្នើសុំចុះឈ្មោះទិញភាគហ៊ុននេះ ខ្ញុំគឺជានិយោជិតរបស់ក្រុមហ៊ុនរបស់ VINCI group ហើយខ្ញុំបានបំពេញលក្ខខណ្ឌដោយបានធ្វើការជានិយោជិតរបស់ VINCI group បានរយៈពេលយ៉ាងតិចប្រាំមួយខែ ក្នុងរយៈពេលដប់ពីរខែកន្លងទៅនេះ។

**ខ្ញុំបានសម្រេចចិត្តធ្វើការវិនិយោគក្នុងការផ្តល់ជូននេះ ក្នុងទឹកប្រាក់ចំនួន (ដែលត្រូវមានចំនួនស្មើ ឬលើសពីតម្លៃគិតជាដុល្លាអាមេរិក ដែលសមមូលនឹងតម្លៃនៃការទិញភាគហ៊ុនរបស់ VINCI ចំនួនមួយ ដោយផ្អែកលើអត្រាប្តូរប្រាក់ដែលកំណត់ដោយ VINCI ក្នុងកាលបរិច្ឆេទកំណត់តម្លៃ)៖** |_|_|_|_|_|_|_|_|_|_|_| USD ដុល្លារអាមេរិក

**ខ្ញុំសម្រេចទូទាត់នូវចំនួនដែលបានបញ្ជាក់ខាងលើ (គូសក្នុងប្រអប់តែមួយប៉ុណ្ណោះ)៖**

☐ **តាមរយៈមូលប្បទានបត្រ** ដោយដាក់ឈ្មោះនិយោជករបស់ខ្ញុំដែលខ្ញុំបានភ្ជាប់ជាមួយនឹងពាក្យស្នើសុំចុះឈ្មោះទិញនេះ។

☐ **ជាសាច់ប្រាក់** ដោយបញ្ជូននូវសាច់ប្រាក់ក្នុងចំនួនដែលត្រូវគ្នានឹងចំនួនដែលបានបញ្ជាក់ខាងលើទៅគណនីដែលបញ្ជាក់ដោយនិយោជករបស់ខ្ញុំ ក្នុងពេលយ៉ាងយូរបំផុតត្រឹមថ្ងៃចុងក្រោយនៃអំឡុងពេលចុះឈ្មោះទិញភាគហ៊ុន។

☐ ជា**ការផ្ទេរតាមរយៈធនាគារ** ដោយបញ្ជូននូវចំនួនដែលត្រូវគ្នានឹងចំនួនដែលបានបញ្ជាក់ខាងលើទៅគណនីដែលបញ្ជាក់ដោយនិយោជករបស់ខ្ញុំ ។*

* សូមបញ្ជាក់ថា ការបង់ប្រាក់របស់អ្នកត្រូវតែទទួលបានយ៉ាងយូរបំផុតត្រឹមថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២២។ ។

---

- **ខ្ញុំបានកត់សំគាល់យ៉ាងត្រឹមត្រូវថា៖**
  - ការផ្តល់ជូននេះត្រូវបានផ្តល់សំរាប់តែនិយោជិតរបស់ VINCI group ដែលមានលក្ខខណ្ឌ គ្រប់គ្រាន់តាមសមត្ថភាពផ្ទាល់ខ្លួនរបស់ពួកគេតែប៉ុណ្ណោះ។ ការចូលរួមក្នុងការផ្តល់ជូននេះ ត្រូវបានហាមឃាត់មិនឱ្យផ្តល់ជូនបុគ្គលផ្សេងទៀត ដែលមិនមែនជានិយោជិតដែលមាន លក្ខខណ្ឌគ្រប់គ្រាន់។
  - ការចុះឈ្មោះទិញក្នុងការផ្តល់ជូននេះ ត្រូវបានគ្រប់គ្រងដោយបញ្ញត្តិនៃផែនការនៃការកាន់កាប់ ភាគហ៊ុនរបស់និយោជិតជាអន្តរជាតិ (International Group Share Ownership Plan) របស់ VINCI group និងដោយពាក្យចុះឈ្មោះស្នើសុំទិញភាគហ៊ុននេះ។
  - ខ្ញុំទិញភាគហ៊ុនរបស់ VINCI តាមរយៈការផ្តល់ជូននេះ តាមរយៈការចុះឈ្មោះទិញនូវឯកតានៃ FCPE CASTOR INTERNATIONAL RELAIS 2022 ដែលនឹងរួមបញ្ចូលជាមួយនឹង FCPE CASTOR INTERNATIONAL ដោយអនុលោមតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជាន់ខ្ពស់របស់ FCPE និងសេចក្តីសម្រេចរបស់ AMF ដែលជា អាជ្ញាធរមូលបត្រប្រទេសបារាំង។
  - ពាក្យស្នើសុំចុះឈ្មោះទិញភាគហ៊ុនរបស់ខ្ញុំនឹងក្លាយជាស្ថាពរ និងមិនអាចដកវិញបានទេ នៅពេលបញ្ចប់រយៈពេលចុះឈ្មោះទិញ។
- **ប្រសិនបើមិនទាន់បានបំពេញត្រឹមត្រូវ ឬមានការភ័ន្តច្រឡំ រាល់ពាក្យស្នើសុំចុះឈ្មោះទិញភាគហ៊ុនអាចត្រូវបានបដិសេធ។ ជាពិសេស VINCI អាចចាត់ទុកថាពាក្យស្នើសុំរបស់ខ្ញុំមិនមានសុពលភាព ប្រសិនបើមិនមានភ្ជាប់ជាមួយនូវ ប្រាក់ថ្លៃភាគហ៊ុនដូចដែលបានកំណត់ខាងលើ។ខ្ញុំសូមយល់ព្រមយ៉ាងច្បាស់លាស់ចំពោះដំណើរការទិន្នន័យផ្ទាល់ខ្លួនរបស់ខ្ញុំក្រោមលក្ខខណ្ឌដែលមានចែងនៅខាងខ្នងនៃពាក្យស្នើសុំនេះ។**

  **ខ្ញុំបានរក្សាទុកលិខិតថតចំលងនៃពាក្យស្នើសុំចុះឈ្មោះទិញនេះចំនួនមួយច្បាប់សំរាប់ជាឯកសារ ផ្ទាល់ខ្លួន។**

---

ធ្វើនៅ ........................................................................ ថ្ងៃទី ........................................................................

ហត្ថលេខា (សូមសរសេរពាក្យ "បានអាន និងឯកភាព")

---

## សេចក្តីអះអាង និងការសន្យា

- ខ្ញុំបានកត់សំគាល់ថា តាមរយៈការវិនិយោគក្នុងការផ្តល់ជូននេះ ខ្ញុំក្លាយទៅជាអ្នកចូលរួមនៅក្នុង ផែនការនៃការកាន់កាប់ភាគហ៊ុនរបស់និយោជិតជាអន្តរជាតិ (International Group Share Ownership Plan) របស់ VINCI group។
- ខ្ញុំយល់ថា ទោះបីជាខ្ញុំនឹងត្រូវបង់ថ្លៃសំរាប់ការវិនិយោគរបស់ខ្ញុំជារូបិយប័ណ្ណដុល្លាអាមេរិក (“USD”) ក៏ដោយ ការចុះឈ្មោះទិញភាគហ៊ុនរបស់ VINCI ត្រូវធ្វើឡើងជារូបិយបណ្ណអឺរ៉ូ (“Euros”) ។ ដូចនេះ ចំនួនទឹកប្រាក់នៃការវិនិយោគរបស់ខ្ញុំនឹងត្រូវប្តូរទៅជាអឺរ៉ូ ដោយផ្អែកទៅតាមអត្រាប្តូរប្រាក់ដែល កំណត់ដោយ VINCI នៅកាលបរិច្ឆេទនៃការកំណត់តម្លៃនេះ (មានន័យថាថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២)។ VINCI ត្រូវបានប្រមាណទុកថានឹងប្រើប្រាស់នូវអត្រាប្តូរប្រាក់ ដែលមានប្រសិទ្ធិភាព អនុវត្តនៅកាលបរិច្ឆេទនោះ។ ក្នុងអំឡុងពេលនៃដំណើរការនៃការវិនិយោគរបស់ខ្ញុំ តម្លៃនៃទ្រព្យសម្បត្តិរបស់ខ្ញុំនឹង ត្រូវទទួលរងឥទ្ធិពលដោយការប្រែប្រួលនៃអត្រាប្តូរប្រាក់រវាងប្រាក់អឺរ៉ូ និង ប្រាក់ដុល្លាអាមេរិក។ អាស្រ័យហេតុនេះ ប្រសិនបើតម្លៃនៃប្រាក់អឺរ៉ូឡើងថ្លៃបើធៀបទៅនឹងប្រាក់ដុល្លាអាមេរិក តម្លៃនៃទ្រព្យសម្បត្តិរបស់ខ្ញុំដែលបង្ហាញជាប្រាក់ដុល្លាអាមេរិកនឹងកើនឡើងផងដែរ។ ផ្ទុយមកវិញ ប្រសិនបើតម្លៃនៃប្រាក់អឺរ៉ូថយចុះបើធៀបទៅនឹងតម្លៃប្រាក់ដុល្លាអាមេរិក តម្លៃនៃទ្រព្យសម្បត្តិរបស់ខ្ញុំដែលបង្ហាញជាប្រាក់ដុល្លាអាមេរិកនឹងធ្លាក់ចុះផងដែរ។
- ខ្ញុំបានកត់សំគាល់យ៉ាងត្រឹមត្រូវថា ប្រសិនបើគ្មានករណីចាកចេញមុនកាលកំណត់ (ដូចដែលបានរៀបរាប់នៅក្នុងខិត្តប័ណ្ណព័ត៌មានសង្ខេប) នោះទេ ការវិនិយោគរបស់ ខ្ញុំនឹងត្រូវបានឃាត់ទុករយៈពេលបី (៣) ឆ្នាំ។
- តាមរយៈសំណើរបស់ខ្ញុំ VINCI ផ្តល់អោយនូវបទប្បញ្ញត្តិរបស់ផែនការនៃការកាន់កាប់ភាគហ៊ុន របស់និយោជិតជាអន្តរជាតិ (International Group Share Ownership Plan) របស់ VINCI group និងរបស់ FCPEs ដែលមានចែងនៅផ្នែកខាងមុខនៃពាក្យស្នើសុំនេះ។

- ភាគហ៊ុនរបស់ VINCI ត្រូវបានចុះបញ្ជីនៅក្នុង Euronext ។ តម្លៃនៃការវិនិយោគរបស់ខ្ញុំនឹងប្រែប្រួលតាមតម្លៃភាគហ៊ុនរបស់ VINCI ដែលអាចឡើង ឬចុះ។ ឯកសារចុះបញ្ជីជាសកលរបស់ VINCI (របាយការណ៍ប្រចាំឆ្នាំ) និងរបាយការណ៍ហិរញ្ញវត្ថុផ្សេងៗទៀត ដែលមានចែងនូវព័ត៌មានសំខាន់ៗស្តីពីសកម្មភាព យុទ្ធសាស្រ្ត ការគ្រប់គ្រង និងលទ្ធផលហរិញ្ញវត្ថុរបស់ VINCI ព្រមទាំងកត្តាហានិភ័យដែលពាក់ព័ន្ធនឹងសកម្មភាពរបស់ VINCI group អាចរកបាននៅ www.vinci.com។ ខ្ញុំសូមបញ្ជាក់ថាខ្ញុំអាចចូលមើលឯកសារទាំងនេះបាន។
- ខ្ញុំបានកត់សំគាល់អំពី ផលវិបាកផ្នែកពន្ធដារ ដែលអាចកើតចេញពីការចូលរួមរបស់ខ្ញុំក្នុង ផែនការនៃការកាន់កាប់ភាគហ៊ុនរបស់និយោជិតជាអន្តរជាតិ (International Group Share Ownership Plan) របស់ VINCI group និងសូមទទួលខុសត្រូវពេញលេញលើបញ្ហានេះ។ ជាពិសេស ខ្ញុំទទួលស្គាល់ថា ខ្ញុំត្រូវសងនិយោជកវិញនូវចំនួនទឹកប្រាក់ទាំងឡាយណា ដែលនិយោជកបានបង់ជាមុនជំនួសខ្ញុំ សំរាប់ថ្លៃបន្ទុកពន្ធដារ ឬបន្ទុករបបសន្តិសុខសង្គមដែលជាក់ស្តែងត្រូវអនុវត្តមកលើរូបខ្ញុំផ្ទាល់។ និយោជករបស់ខ្ញុំ អាចកាត់នូវចំនួនទឹកប្រាក់នេះចេញពីប្រាក់បៀវត្សរបស់ខ្ញុំ ឬពីប្រាក់ផ្សេងទៀតដែលត្រូវបង់មកអោយខ្ញុំ និង/ឬអាចបញ្ជាអោយលក់នូវឯកតា FCPE ឬភាគហ៊ុនរបស់ខ្ញុំមួយផ្នែក ឬទាំងអស់ និងកាត់ទុកពីប្រាក់ចំណូលពីការលក់នេះ។
- សេចក្តីសំរេចរបស់ខ្ញុំក្នុងការចូលរួម ឬមិនចូលរួមនៅក្នុងការផ្តល់ជូននេះ ត្រូវបានធ្វើឡើងដោយ ស្ម័គ្រចិត្ត និងផ្ទាល់ខ្លួនទាំងស្រុង។ សេចក្តីសំរេចរបស់ខ្ញុំនឹងមិនមានឥទ្ធិពល មិនថាវិជ្ជមាន ឬអវិជ្ជមានក្តី ទៅលើការងាររបស់ខ្ញុំនៅក្នុង VINCI group ឡើយ។ ការចូលរួមនៅក្នុងការផ្តល់ជូននេះមានលក្ខណៈដាច់ដោយឡែក និងមិនមែនជាផ្នែកមួយនៃកិច្ចសន្យាការងាររបស់ខ្ញុំឡើយ ហើយមិនបានផ្តល់អោយខ្ញុំនូវសិទ្ធិ ឬអំណាចណាមួយដែលទាក់ទងនឹងការងាររបស់ខ្ញុំ (រួមមានការគណនាការបង់ប្រាក់អតីតភាពការងារ ប្រសិនបើពាក់ព័ន្ធ) ឬផលប្រយោជន៍ដែលពាក់ព័ន្ធ ឬសិទ្ធិអំណាចណាមួយឡើយ រាប់បញ្ចូលទាំងការបញ្ចប់កិច្ចសន្យា។
- ខ្ញុំក៏បានកត់សំគាល់ទៀតថា ឯកសារនេះ និងលិខិតផ្សេងៗទៀតដែលត្រូវបានចែកចាយ ឬអាចផ្តល់មកអោយខ្ញុំទាក់ទងនឹងការផ្តល់ជូននេះ ឬ ផែនការនៃការកាន់កាប់ភាគហ៊ុនរបស់និយោជិតជាអន្តរជាតិ (International Group Share Ownership Plan) របស់ VINCI group មិនផ្តល់ អោយខ្ញុំនូវសិទ្ធិឬអំណាចណាមួយទាក់ទងនឹងការផ្តល់ជូនណាមួយនាពេលអនាគតឡើយ។
- ការវិនិយោគរបស់ខ្ញុំ នឹងត្រូវបានបំពេញបន្ថែមដោយការផ្តល់ភាគហ៊ុនដោយគ្មានតម្លៃតបស្នង ដែលធ្វើឡើងដោយ VINCI។ សេចក្តីលំអិតទាក់ទងនឹងបញ្ហានេះ ត្រូវបានរៀបរាប់នៅក្នុងខិត្តប័ណ្ណព័ត៌មានសង្ខេប។ រាល់ខ និងលក្ខខណ្ឌទាំងឡាយដែលគ្រប់គ្រងសិទ្ធិក្នុងការទទួលបានភាគហ៊ុនបន្ថែម មានចែងក្នុងវិធាននានានៃផែនការនៃការកាន់កាប់របស់និយោជិតជាអន្តរជាតិ (International Group Share Ownership Plan) របស់ VINCI group ហើយខ្ញុំត្រូវបានលើកទឹកចិត្តឱ្យអានខ និងលក្ខខណ្ឌទាំងនោះ។
- ខ្ញុំសូមបញ្ជាក់ថា ប្រាក់ដែលខ្ញុំបង់សម្រាប់ការវិនិយោគនៅក្នុងផែនការនៃការកាន់កាប់ភាគហ៊ុនរបស់និយោជិតជាអន្តរជាតិ (International Group Share Ownership Plan) របស់ VINCI group ក្នុងឆ្នាំ២០២២ នឹងមិនលើសពី ២៥% នៃប្រាក់សំណងដុលប្រចាំឆ្នាំរបស់ខ្ញុំដែលត្រូវបានប៉ាន់ស្មានសម្រាប់ឆ្នាំ២០២២ ឡើយ។ គោលបំណងនៃការគណនានេះ ខ្ញុំនឹងគិតពិចារណាអំពីប្រាក់ខែដែលបានបង់ឲ្យខ្ញុំចាប់តាំងពីថ្ងៃទី១ ខែមករា ឆ្នាំ២០២២ ហើយធ្វើការប៉ាន់ស្មានអំពីប្រាក់ខែដែលខ្ញុំគួរទទួលបានរហូតដល់ដំណាច់ឆ្នាំ២០២២ ដោយផ្អែកលើកិច្ចសន្យាការងាររបស់ខ្ញុំ។ តួលេខទាំងអស់ដែលបានរក្សាទុកសម្រាប់ការគណនានេះជាចំនួនសរុប ពោលគឺមុនពេលបង់ពន្ធកាត់ទុក និងរបបសន្តិសុខសង្គមដែលអាចមាន។
- ចំនួនភាគហ៊ុនដែលមានក្នុងការផ្តល់ជូននេះ គឺ ៨ ០៨៥ ៩៧៧។ ប្រសិនបើចំនួនសរុបនៃសំណើរ ចុះឈ្មោះទិញលើសពីចំនួនភាគហ៊ុនដែលមានសំរាប់ការផ្តល់ជូននេះ ចំនួនទឹកប្រាក់នៃការវិនិយោគរបស់ខ្ញុំនឹងត្រូវកាត់បន្ថយ។ ចំនួនដែលត្រូវកាត់បន្ថយនេះនឹងត្រូវគណនាដូចខាងក្រោម៖

  (i) កម្រិតកំណត់ដាច់ដោយឡែកមួយនឹងត្រូវបានគណនាអោយស្មើនឹង សំណើរចុះឈ្មោះទិញជា មធ្យម ដែលគណនាដោយផ្អែកលើចំនួននៃសំណើរចុះឈ្មោះទិញសរុប។ សំណើរចុះឈ្មោះទិញនឹងត្រូវទទួលយកយ៉ាងពេញលេញរហូតដល់កម្រិតដែលកំណត់នេះ។

  (ii) បន្ទាប់មក ចំនួនភាគហ៊ុនដែលនៅសល់នឹងត្រូវបានកំណត់ ហើយសមាមាត្រនៃការកាត់បន្ថយ នឹងត្រូវគណនាដើម្បីយកទៅអនុវត្តចំពោះសំណើរចុះឈ្មោះទិញនីមួយៗដែលនៅសល់។

ខ្ញុំយល់ព្រមកាត់បន្ថយចំនួនវិនិយោគរបស់ខ្ញុំតាមនោះដែរ។ ចំនួនទឹកប្រាក់ដែលស្របទៅនឹងសំណើរ ចុះឈ្មោះទិញដែលមិនអាចធ្វើទៅបាន នឹងត្រូវសងមកអោយខ្ញុំវិញ ទៅតាមកម្រិតនៃការបង់ប្រាក់ ដោយស្ម័គ្រចិត្តរបស់ខ្ញុំ ឬចំនួនដែលត្រូវកាត់ទុកត្រូវកាត់បន្ថយ។ ការបង់ប្រាក់នឹងត្រូវធ្វើដោយយោងទៅតាមលក្ខខណ្ឌដែលបានផ្តល់អោយនៅព្រះរាជាណាចក្រកម្ពុជា។

- **ខ្ញុំបានកត់សំគាល់ថា ប្រសិនបើខ្ញុំខកខានមិនបានបង់ ឬមិនធ្វើការបង់ប្រាក់សំរាប់ការវិនិយោគ របស់ខ្ញុំតាមពេលវេលាកំណត់ទេនោះ ការស្នើសុំទិញភាគហ៊ុននេះអាចត្រូវបានលុបចោលដោយមិនចាំបាច់មានការផ្តល់ដំណឹងឡើយ។ ប្រសិនបើការស្នើសុំទិញរបស់ខ្ញុំត្រូវបានដំណើរការខ្ញុំនឹងនៅតែមានទំនួលខុសត្រូវ សម្រាប់ទឹកប្រាក់នៃការចុះឈ្មោះទិញរបស់ខ្ញុំ (។ ខ្ញុំទទួលស្គាល់ និងយល់ព្រមយ៉ាងច្បាស់លាស់ថា VINCI អាចលោះត្រឡប់វិញ ឬបានលោះមកវិញនូវរាល់ឯកតា FCPE និងឬ/ភាគហ៊ុនរបស់ខ្ញុំទាំងអស់ និងកាត់កងប្រាក់ដែល ទទួលបានមកពីការលក់មកធ្វើការទូទាត់ថ្លៃទិញរបស់ខ្ញុំដោយមិនចាំបាច់មានការជូនដំណឹងជាមុនឡើយ។ ប្រសិនបើប្រាក់ដែលទទួលបានមកពីការលក់ មិនគ្រប់គ្រាន់នឹងទូទាត់សងចំនួនទឹកប្រាក់ដែលបានបង្ហាញខាងលើ ខ្ញុំនឹងនៅ ជំពាក់ VINCI SA នូវចំនួនទឹកប្រាក់ដែលសមមូលនឹងប្រាក់ជំពាក់។ បន្ថែមពីនេះ VINCI SA នៅរក្សាសិទ្ធិក្នុងការដាក់ពាក្យបណ្តឹងចំពោះរូបខ្ញុំ ដើម្បីទាមទារប្រាក់ដែលនៅជំពាក់ ។**

**បម្រាម៖**

ការផ្តល់ជូននេះ គឺសម្រាប់តែនិយោជិតរបស់ VINCI group ដែលមានលក្ខខណ្ឌគ្រប់គ្រាន់តាម សមត្ថភាព ផ្ទាល់ខ្លួនរបស់ពួកគេតែប៉ុណ្ណោះ។ ការចូលរួមក្នុងការផ្តល់ជូននេះ ត្រូវបានហាមឃាត់មិនឱ្យ ផ្តល់ជូន បុគ្គលផ្សេងទៀត ដែលមិនមែនជានិយោជិតដែលមានលក្ខខណ្ឌគ្រប់គ្រាន់។ ប្រការនេះមាន ន័យថា ប្រសិនបើលោកអ្នកជានិយោជិតដែលមានលក្ខខណ្ឌគ្រប់គ្រាន់ លោកអ្នកមិនអាចផ្តល់ការចូលរួមក្នុង ការផ្តល់ជូននេដោយផ្ទាល់ ឬ ដោយប្រយោលទៅឱ្យមិត្តភក្តិ គ្រួសារ ឬបុគ្គលផ្សេងទៀតឡើយ។ ទាំងនេះរាប់បញ្ចូលទាំងការចាត់ចែងណាមួយដែលតាមរយៈនោះ អ្នកទទួលបានហរិញ្ញប្បទានជាថ្នូរ នឹងការផ្តល់ភាគហ៊ុនដើម្បីទទួលបានប្រាក់ចំណេញ។

VINCI រក្សាសិទ្ធិក្នុងការចាត់វិធានការដែលខ្លួនយល់ថាចាំបាច់ ឬដែលសមគួរដើម្បីធានាអនុលោមភាពជាមួយនឹងការហាមឃាត់ក្នុងការផ្តល់ការចូលរួមក្នុងការផ្តល់ជូននេះ ទៅឱ្យបុគ្គលណាមួយដែល មិនមែនជានិយោជិតដែលមានលក្ខខណ្ឌគ្រប់គ្រាន់។ វិធានការនេះអាចរាប់បញ្ចូលទាំងការតម្រូវ អោយអ្នកចូលរួមក្នុងការផ្តល់ជូននេះផ្តល់ភស្តុតាង ដែលបញ្ជាក់ថាថវិការដែលពួកគេប្រើប្រាស់ដើម្បី ទិញភាគហ៊ុនបានមកពីធនធានផ្ទាល់របស់ពួកគេ។ ប្រសិនបើ VINCI ជឿជាក់ ឬសង្ស័យថា (ទោះក្នុង ពេលណាក៏ដោយ និង ដោយពុំចាំបាច់ជូនដំណឹងជាមុន) បុគ្គលណាមួយបាន ឬអាចបំពានលើវិធាននេះ ឬលក្ខខណ្ឌផ្សេងទៀតនៃការផ្តល់ជូននេះ ទៅតាមការកំណត់ក្នុងច្បាប់ដែលពាក់ព័ន្ធ VINCI អាច (i) បដិសេធ ឬលុបចោល ពាក្យស្នើសុំចុះឈ្មោះទិញភាគហ៊ុនរបស់បុគ្គលនោះ និង ឬ/(ii) ធ្វើអោយមានការលក់ភាគហ៊ុនណាមួយដែលបានបែងចែកទៅអោយបុគ្គលនោះ និងដកហូតពីប្រាក់ដែលទទួលបានពីការលក់នូវប្រាក់ចំណេញ ការចំណាយ និងឬ ទឹកប្រាក់ដែល/ត្រូវបានកេងបន្លំ និង ឬ/(iii) បង្កកគណនីផែនការសន្សំរបស់បុគ្គលនោះ និង/ឬ (iv) កាត់ទុកទឹកប្រាក់ដែលត្រូវបានកេងបន្លំ ពីចំនួនទឹកប្រាក់ផ្សេងៗដែលត្រូវផ្តល់អោយ ទៅបុគ្គលនោះ ដោយក្រុមហ៊ុនណាមួយរបស់ VINCI group (រាប់បញ្ចូលទាំងប្រាក់បៀវត្សរបស់ពួកគេ)។

VINCI រក្សាសិទ្ធិក្នុងការលុបចោល ឬកែប្រែការផ្តល់ជូននេះ ទាំងមូលឬមួយផ្នែកនៅគ្រប់ពេលវេលាទាំងអស់ ដោយយោងទៅតាមឆន្ទានុសិទ្ធិផ្តាច់មុខរបស់ខ្លួនផ្ទាល់។ គ្មានសំណងណាមួយត្រូវ បានចាត់ទុកថា នៅជំពាក់ ឬត្រូវបានផ្តល់អោយសំរាប់ការបាត់បង់នូវទឹកចិត្ត ឬផលចំណេញនាពេល អនាគត ណាមួយឡើយ ក្នុងករណីលុបចោល ឬកែប្រែនេះ។

- ខ្ញុំបានយល់ថា ការផ្តល់ជូននេះមិនផ្តល់ឲ្យ “ជនជាតិអាមេរិក” ហើយខ្ញុំបញ្ជាក់ថា ខ្ញុំមិនមែនជាអ្នកស្នាក់នៅសហរដ្ឋអាមេរិកឡើយ។ ខ្ញុំយល់ថាព័ត៌មានបន្ថែមអំពីការរឹតបន្តឹងនេះ មាននៅក្នុងបទប្បញ្ញត្តិរបស់ FCPE និង នៅលើគេហទំព័ររបស់ក្រុមហ៊ុនគ្រប់គ្រង ដែលអាចចូលប្រើបានតាមរយ: castor.vinci.com។
- ខ្ញុំយល់ថា នាពេលបច្ចុប្បន្ន មិនមានច្បាប់ជាក់លាក់ណាមួយដែលគ្រប់គ្រងការផ្តល់ជូនក្នុងប្រទេសកម្ពុជា។ ក្នុងករណីនៃការអនុម័តច្បាប់ ឬ ការអនុម័ត បទប្បបញ្ញត្តិ VINCI រក្សាសិទ្ធិក្នុងការប្រែលក្ខខណ្ឌនៃការផ្តល់ជូននេះតាមកម្រិតដែលតម្រូវតាមច្បាប់នៃប្រទេសកម្ពុជា។ ខ្ញុំយល់ព្រម ក្នុងការចង់ភ្ជាប់ដោយការកែប្រែទាំងអស់នោះ និង/ឬ កាតព្វកិច្ចផ្លូវច្បាប់បន្ថែមដែលទាមទារនៅក្រោមច្បាប់នៃប្រទេសកម្ពុជា ដើម្បីអនុវត្តការផ្តល់ជូននៅក្នុងប្រទេសកម្ពុជាប្រកបដោយប្រសិទ្ធភាព។

## ដំណើរការទិន្នន័យផ្ទាល់ខ្លួន

ខ្ញុំបានយល់ថា ទិន្នន័យផ្ទាល់ខ្លួនរបស់ខ្ញុំដែលមាននៅក្នុងពាក្យស្នើសុំនេះត្រូវប្រើក្នុងបរិបទនៃការដំណើរការទិន្នន័យ។ ការដំណើរការនេះ ស្ថិតនៅក្រោមបទប្បញ្ញត្តិច្បាប់បារាំងលេខ ៧៨-១៧ នៃខែមករា ឆ្នាំ១៩៧៨ ស្តីពីការដំណើរការទិន្នន័យ ឯកសារទិន្នន័យ និងសេរីភាពបុគ្គល ព្រមទាំងបទប្បញ្ញត្តិរបស់សហគមន៍អឺរ៉ុបស្តីពីការការពារទិន្នន័យ (២០១៦/៦៧៩)។

ទិន្នន័យផ្ទាល់ខ្លួនដែលមាននៅក្នុងពាក្យស្នើសុំនេះត្រូវដំណើរការដោយផ្អែកលើការយល់ព្រមរបស់ខ្ញុំតាមរយៈពាក្យស្នើសុំនេះ និងដោយហេតុថា វាចាំបាច់ក្នុងការអនុវត្តកិច្ចសន្យាចុះឈ្មោះទិញ និងក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ខ្ញុំក្នុងក្របខណ្ឌនៃផែនការនៃ ការកាន់កាប់ភាគហ៊ុន របស់និយោជិតជាអន្តរជាតិ (International Group Share Ownership Plan) របស់ VINCI group។ ខ្ញុំទទួលស្គាល់ថា ទិន្នន័យផ្ទាល់ខ្លួនរបស់ខ្ញុំនឹងត្រូវបានរក្សាទុកក្នុងរយៈពេលដែលចាំបាច់ក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ខ្ញុំ (យ៉ាងហោចណាស់ត្រូវស្របទៅនឹងរយៈពេលហាមឃាតការលក់ (lock-up period) ដែលបានកំណត់ក្រោមផែនការនេះ) និងបន្ទាប់ពីការរំលោះទ្រព្យសម្បត្តិសម្រាប់គោលបំណងរក្សាទុករហូតដល់ផុតកំណត់នៃរយៈពេលនៃជម្លោះដែលអាចកើតមាន។

អ្នកបញ្ជាលើដំណើរការទិន្នន័យគឺ ក្រុមហ៊ុន VINCI S.A . ដែលមានការិយាល័យក្រុមហ៊ុននៅ1 , cours Ferdinand de Lesseps, 92500 Rueil-Malmaison, France ។ ទិន្នន័យផ្ទាល់ខ្លួនរបស់ខ្ញុំនឹងត្រូវបានដំណើរការដោយក្រុមហ៊ុន VINCI S.A. និយោជកក្នុងស្រុករបស់ខ្ញុំ និង ដោយ AMUNDI ESR ដែលមានការិយាល័យចុះបញ្ជីនៅ 90 boulevard Pasteur, 75015 Paris, France (postal address 26956 VALENCE CEDEX 9, FRANCE) ដែលត្រូវបានតែងតាំងដោយក្រុមហ៊ុន VINCI S.A. ឱ្យប្រតិបត្តិរាល់ប្រតិបត្តការដែលពាក់ព័ន្ធនឹងសំណើរចុះឈ្មោះទិញរបស់ខ្ញុំ ការរក្សាគណនី និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ខ្ញុំ ក្នុងក្របខណ្ឌនៃផែនការនៃការកាន់កាប់ភាគហ៊ុនរបស់និយោជិតជាអន្តរជាតិ (International Group Share Ownership Plan)។ ខ្ញុំកត់សំគាល់ជាពិសេសថា ទិន្នន័យផ្ទាល់ខ្លួនរបស់ខ្ញុំនឹងត្រូវបានផ្ទេរក្នុងបរិបទនេះ ទៅឱ្យអ្នកផ្តល់សេវាទាំងនេះនៅប្រទេសបារាំង។

ខ្ញុំមានសិទ្ធិក្នុងការស្នើសុំចូលមើល កែប្រែ កែតម្រូវ ឬលុបចោល (បន្ទាប់ពីការលោះទ្រព្យសម្បត្តិរបស់ខ្ញុំទាំងអស់ដែលមានក្នុងគម្រោង) នូវទិន្នន័យផ្ទាល់ខ្លួនរបស់ខ្ញុំ និងសិទ្ធិក្នុងការស្នើសុំការរឹតត្បិតលើការដំណើរការទិន្នន័យរបស់ខ្ញុំ ឬតវ៉ាចំពោះការដំណើរការ ព្រមទាំងសិទ្ធិក្នុងការដាក់ពាក្យបណ្តឹងទៅអាជ្ញាធរត្រួតពិនិត្យ ដូចជា French CNIL (www.cnil.fr)។ ដើម្បីអនុវត្តសិទ្ធិរបស់ខ្ញុំដែលពាក់ព័ន្ធនឹងការដំណើរការទិន្នន័យផ្ទាល់ខ្លួនរបស់ខ្ញុំ ខ្ញុំត្រូវទំនាក់ទំនងទៅ បុគ្គលិកផ្នែកការពារទិន្នន័យរបស់ VINCI S.A. តាមរយៈ contact.dpo@vinci.com ។

ព័ត៌មានស្តីពីដំណើការទិន្នន័យផ្ទាល់ខ្លួននៅក្នុងបរិបទនៃគម្រោង VINCI Castor International Share Plan បានផ្តល់ជូននៅក្នុង "សេចក្តីជូនដំណឹងស្តីពីការការពារទិន្នន័យផ្ទាល់ខ្លួនរបស់អ្នក" ដែលមាននៅ castor.vinci.com។